**ហិង្សាផ្លូវភេទ** (sexual violence)

វាត្រូវបានផ្តល់ន័យទូលាយថា ជាទង្វើពាក់ព័ន្ធផ្លូវភេទ ប្រព្រឹត្តលើបុគ្គល ក្នុងកាលៈទេសៈបង្ខំ (Kvocka, IT-98-30/1-T, 2001)។ ហិង្សាលើផ្លូវភេទនេះ គ្របលើបទល្មើសជាច្រើន ដូចជា ការរំលោភសេពសន្ថវៈ (rape) ទាសករភេទ (sexual slavery) ការស្ទាបអង្អែល (molestation) ការកាត់អង្គជាត (sexual mutilation) ការរៀបការដោយបង្ខំ (forced marriage) ការរំលូតកូនដោយបង្ខំ (forced abortion) ពេស្យាចារដោយបង្ខំ (forced prostitution) មានគ៌ភដោយបង្ខំ (forced pregnancy) និង ពន្យាកំណើតដោយបង្ខំ (sterilization) (Kvocka)។

ហិង្សាលើផ្លូវភេទ មានចែងក្នុង GC IV មាត្រា ២៧ និងអនុសញ្ញាដទៃទៀតដូចជាពិធីសារបន្ថែមទី១ (មាត្រា ៧៦)។ វាមិនត្រូវបានដាក់បញ្ចូលក្នុងការបំពានបំពារធ្ងន់ធ្ងរទេ (grave breaches)។ យុត្តិសាស្ត្របន្តបន្ទាប់ ព្យាយាមបកស្រាយបញ្ចូលទៅក្នុងបទល្មើសអំពើអមនុស្សធម៌ដទៃទៀត (other inhumane acts) នៃបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (crime against humanity)។ បន្ថែមពីលើនេះ វាអាចបទល្មើសក្នុងបទឧក្រិដ្ឋប្រល័យពូជសាសន៍ (genocide) ប្រសិនបើនាំការឈឺចាប់ផ្លូវចិត្ត ឬរបួសរាងកាយធ្ងន់ធ្ងរ ដល់សមាជិកនៃក្រុមមនុស្សជាទិសដៅ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 513-514)។